# សង្គមស៊ីវិលស្នើកម្ពុជានិងអ៊ីតាលីបញ្ឈប់ការសុំកូនជាបន្ទាន់ដើម្បីបញ្ចៀសការរំលោភសិទ្ធិកុមារ




នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការឃ្លាំមើលសិទ្ធិមនុស្សលីកាដូ (Licadho) លោក អំ សំអាត ចូលរួមវេទិកាវិទ្យុអាស៊ីសេរី នាពេលកន្លងទៅ។

អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិចំនួន ៩ស្ថាប័ន បានរួមគ្នាចេញសេចក្តីថ្លែងការណ៍មួយ ស្នើសុំឱ្យរដ្ឋាភិបាលកម្ពុជា និងប្រទេសអ៊ីតាលី បញ្ឈប់ជាបន្ទាន់ក្នុងការដំណើរការនីតិវិធីសុំកូនពីប្រទេសកម្ពុជា។ មន្ត្រីអង្គការសង្គមស៊ីវិលលើកឡើងថា ការស្នើសុំនេះគឺដើម្បីបញ្ចៀសការរំលោភបំពានសិទ្ធិកុមារ តាមរយៈការសុំកូនឆ្លងប្រទេស ដូចដែលធ្លាប់កើតមានកន្លងមក។

អង្គការការពារសិទ្ធិមនុស្សលីកាដូ (LICADHO) មជ្ឈមណ្ឌលការពារសិទ្ធិមនុស្ស (CCHR) សមាគមការពារសិទ្ធិមនុស្ស អាដហុក (ADHOC) រួមជាមួយអង្គ

ការបរទេស ឈ្មោះថា សំឡេងការសុំកូនអន្តរប្រទេស (Intercountry Adoptee Voices) បានចេញសេចក្តីថ្លែងការណ៍រួមគ្នាមួយ កាលពីថ្ងៃទី២៨ ខែមិថុនា ស្នើសុំឱ្យរដ្ឋាភិបាលកម្ពុជា និងប្រទេសអ៊ីតាលី បញ្ឈប់ជាបន្ទាន់ក្នុងការបើកដំណើរឡើងវិញ លើនីតិវិធីសុំកូនពីកម្ពុជា ទៅអ៊ីតាលី។

ក្រុមអង្គការទាំងនេះ លើកឡើងក្នុងសេចក្តីថ្លែងការណ៍ថា រដ្ឋាភិបាលកម្ពុជាគួរបំពេញតួនាទីលើកកម្ពស់ការថែទាំសុខុមាលភាពកុមារ ឱ្យទទួលបានការលូតលាស់ប្រកបដោយគុណភាពនៅក្នុងប្រទេស ជាជាងផ្តល់ការអនុញ្ញាតឱ្យមានការសុំកូនទៅប្រទេសក្រៅ ដែលធ្វើឱ្យកុមារត្រូវបានគេសុំ ត្រូវរងការរំលោភបំពានសិទ្ធិ និងបាត់បង់ទំនាក់ទំនងគ្រួសាររបស់ខ្លួន។ អង្គការសង្គមស៊ីវិលបន្តថា បើទោះបីជាមានច្បាប់ និងគោលនយោបាយថ្មីៗ ដើម្បីធានាអំពីការសុំកូនដោយសុវត្ថិភាពក្តី ប៉ុន្តែនីតិវិធីទាំងនោះនៅតែមិនអាចលុបបំបាត់បញ្ហាក្លែងបន្លំឯកសារ ប្តូរឈ្មោះ ថ្ងៃខែកំណើតកុមារ និងអំពើពុករលួយ ក្នុងដំណើរការសុំកូនបានឡើយ។

ក្រោយពីមានសេចក្តីរាយការណ៍ជាច្រើនពីអំពើខុសក្រមសីលធម៌ និងរំលោភច្បាប់ស្តីពីការសុំកូន រដ្ឋាភិបាលកម្ពុជា និងប្រទេសជាច្រើនបានហាមឃាត់ការសុំកូនឆ្លងប្រទេសក្នុងឆ្នាំ២០០៩។ ប៉ុន្តែនៅក្នុងខែឧសភា កន្លងទៅកម្ពុជា និងអ៊ីតាលី បានចាប់ផ្តើមបោះជំហានទៅរកការបើកឱ្យមានការសុំកូនពីកម្ពុជាឡើងវិញ ដោយគណៈកម្មការសុំកូនអន្តរប្រទេសអ៊ីតាលី បានបង្ហាញថា អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស នៃក្រសួងសង្គមកិច្ចកម្ពុជា បានអនុញ្ញាតឱ្យភ្នាក់ងារសុំកូនអ៊ីតាលីចំនួន៣ ដំណើរការក្នុងប្រទេសកម្ពុជា និងភ្នាក់ងារសុំកូនអ៊ីតាលីចំនួន៣ទៀត កំពុងរង់ចាំទទួលបានការអនុញ្ញាតដំណើរការ។ បន្ថែមពីនេះ គណៈកម្មការសុំកូនអន្តរប្រទេសអ៊ីតាលីបានលើកឡើងថា នីតិវិធីសុំកូនចំនួន៩នាក់ កំពុងរង់ចាំការសម្រេច។

របាយការណ៍ការអង្គការការពារសិទ្ធិមនុស្សលីកាដូ (Licadho) ឆ្នាំ២០១៨ បង្ហាញថា ចាប់ពីទសវត្សរ៍ឆ្នាំ១៩៨០ រហូតដល់ឆ្នាំ២០០៩ កុមារកម្ពុជាជាច្រើនពាន់នាក់ត្រូវបានគេសុំយកទៅចិញ្ចឹមនៅក្រៅប្រទេស។ ទោះជាយ៉ាងណា កុមារទាំងនោះជាច្រើននាក់មិនមែនជាកុមារកំព្រានោះឡើយ ដោយពួកគេត្រូវបានឪពុកម្ដាយយកទៅដាក់នៅមណ្ឌលកុមារកំព្រា ដោយសារតែកត្តាជីវភាពក្រីក្រ។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងអ្នកនាំពាក្យក្រសួងសង្គមកិច្ច លោក តូច ចាន់នី និងអ្នកនាំពាក្យគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាល លោក កត្តា អ៊ន ដើម្បីបកស្រាយជុំវិញរឿងនេះបានទេ នៅថ្ងៃទី២៩ ខែមិថុនា។ ទោះជាយ៉ាងណា លោក តូច ចាន់នី បានឆ្លើយតបសារព័ត៌មាន ខេមបូចា (CamboJa) ថា រដ្ឋាភិបាលកម្ពុជាបើកឱ្យដំណើរការសុំកូនឆ្លងប្រទេសឡើងវិញដោយសារតែកម្ពុជាបានធ្វើសេចក្ដីព្រាងច្បាប់ ដែលមានការគាំពារគ្រប់គ្រាន់ពេលបញ្ជូនកុមារទៅបរទេស។ លោកបញ្ជាក់ថា កម្ពុជាបានផ្អាកដំណើរការសុំកូន ដោយសារតែមិនទាន់មានច្បាប់សុំកូនប្រកបដោយប្រសិទ្ធភាព។

ជុំវិញរឿងនេះ នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការឃ្លាំមើលសិទ្ធិមនុស្សលីកាដូ លោក អំ សំអាត មានប្រសាសន៍ថា មូលហេតុដែលក្រុមអង្គការសង្គមស៊ីវិលស្នើសុំឱ្យរដ្ឋាភិបាល បញ្ឈប់ការអនុញ្ញាតឱ្យមាននីតិវិធីសុំកូនឡើងវិញ គឺដើម្បីធានាកុំឱ្យមានការរំលោភសិទ្ធិកុមារ តាមរយៈការសុំកូនអន្តរប្រទេសឡើងវិញ។ លោកបន្ថែមថា ដោយសារអំពើពុករលួយ និងការអនុវត្តច្បាប់នៅកម្ពុជានៅតែមានភាពទន់ខ្សោយ ដូច្នេះ បើទោះបីជាមាននីតិវិធីថ្មីៗ ដើម្បីធានាការសុំកូនដោយសុវត្ថិភាព ប៉ុន្តែក្រុមអង្គការសង្គមស៊ីវិលនៅតែព្រួយបារម្ភចំពោះការក្លែងបន្លំឯកសារក្នុងដំណើរការសុំកូន។

លោក អ៊ំ សំអាត៖ «*យើងមិនចង់ឃើញរាជរដ្ឋាភិបាល ឬក៏អាជ្ញាធរយើងបើកឡើងវិញទាំងប្រថុយប្រថានលើការសុំកូនអន្តរប្រទេសនេះទេ គឺយើងចង់ឱ្យមានការធ្វើឱ្យប្រាកដ និងការកែលម្អឡើងវិញទៅលើប្រព័ន្ធនៃកិច្ចការពារកុមារ ទាក់ទងនឹងការសុំកូនអន្តរប្រទេសនេះ ដើម្បីជាការលើកកម្ពស់ទៅលើសិទ្ធិកុមារ និងកិច្ចការពារកុមារឱ្យបានគ្រប់គ្រាន់កុំឱ្យដូចពេលកន្លងមក*»។

វិទ្យុអាស៊ីសេរី មិនអាចសុំការបកស្រាយអំពីបញ្ហានេះ ពីអគ្គកុងស៊ុលអ៊ីតាលីប្រចាំប្រទេសកម្ពុជា បាននៅឡើយទេ គិតត្រឹមថ្ងៃទី២៩ ខែមិថុនា។

អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ លើកឡើងថា រដ្ឋាភិបាលកម្ពុជាមិនត្រូវអនុញ្ញាតឱ្យមានការសុំកូនអន្តរប្រទេសឡើងវិញទេ។ ដើម្បីបញ្ចៀសការរំលោភសិទ្ធិកុមារ និងការរស់នៅឃ្លាតឆ្ងាយពីគ្រួសារកំណើត ក្រុមអង្គការសង្គមស៊ីវិលជំរុញឱ្យរដ្ឋាភិបាលលើកកម្ពស់ការថែទាំ និងផ្ដល់ការអប់រំទៅដល់កុមារតាមគ្រួសារ និងសហគមន៍ ជាជាងអនុញ្ញាតឱ្យកុមារទៅរស់នៅជាមួយឪពុកម្ដាយថ្មី និងគ្មានវិធានការតាមដានដោយប្រសិទ្ធភាព៕